# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ១០៤ ជនស/អសណ

ថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំរោងឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០២៤

**ជម្រាបមក**

**លោក សែ អង្គលីន**

**កម្មវត្ថុ** : ករណីសំណើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់អគារពាណិជ្ជកម្មពហុមុខងារ លេខ ០៩៩ ជនស/អសណ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**យោង** :
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសអន្តរក្រសួងលេខ ៣៥៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតសាងសង់ និងប្លង់ស្ថាបត្យកម្មលេខ ០៩៩ ជនស/អសណ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ពាក្យស្នើសុំចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០២៤ របស់ក្រុមហ៊ុន ស្យុងវៃ អ៊ិនវេសម៉ិន ឯ.ក តំណាងដោយលោក **សែ អង្គលីន**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក** ជ្រាបថា លិខិតអនុញ្ញាតសាងសង់អាចបន្តសុពលភាពបានតែមួយដងគត់។ ចំពោះសំណើសុំខាងលើនេះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុញ្ញាតឱ្យបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់លេខ ០៩៩ ជនស/អសណ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលមួយឆ្នាំបន្តទៀតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អាស្រ័យហេតុនេះ សូម **លោក** ជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើ។

សូម **លោក** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**សុខ គាង**

**កន្លែងទទួល**

- រដ្ឋបាលរាជធានីភ្នំពេញ
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ
- ការិយាល័យច្រកចេញចូលតែមួយ
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com